Khmer

**Language Fact Sheet – About HomeStart** (សន្លឹកពត៌មានផ្នែកភាសា - អំពី **HomeStart**)

ប្រសិនបើលោកអ្នកមានបំណងចង់ទិញផ្ទះផ្ទាល់ខ្លួនរបស់លោកអ្នក ហើយកំពុងស្វែងរកប្រាក់ខ្ចីទិញផ្ទះដ៏ត្រឹមត្រូវ HomeStart  (ហូមស្តាត) អាចជួយលោកអ្នក ចាប់ផ្តើមដំណើរការ។

ទោះថាលោកអ្នកកំពុងស្វែងរកទិញផ្ទះលើកដំបូងរបស់លោកអ្នក ឬផ្ទះបន្ទាប់មួយទៀតក្តី ឬមានបំណងចង់សាងសង់ ឬខ្ចីប្រាក់ម្តងទៀត- HomeStart មានប្រាក់ ខ្ចីទិញផ្ទះដែលអាចជួយលោកអ្នកសំរេចបាននូវគោលដៅរបស់លោកអ្នក។

## ហេតុអ្វីបានជាត្រូវការជ្រើសរើសយក HomeStart?

ដើម្បីជួយលោកអ្នករើចូលផ្ទះរបស់លោកអ្នកបានឆាប់ជាង យើងមានប្រាក់ខ្ចីទិញផ្ទះដែលមានលក្ខណ:ពិសេសៗមួយចំនួនធំ មានរួមទាំង:

- ប្រាក់ខ្ចីទិញផ្ទះដែលជួយបង្កើនចំនួនប្រាក់ដែលលោកអ្នកអាចខ្ចី
- ជំរើសប្រាក់កក់ដែលមានចំនួនតិច
- ឥតមានបង់ថ្លៃធានារ៉ាប់រងសំរាប់អ្នកឲ្យខ្ចីប្រាក់ឡើយ (LMI) - ជាជំនួសវិញនោះ HomeStart មានការគិតថ្លៃលើប្រាក់ខ្ចីទិញផ្ទះ (Loan Provision Charge) ដែលមានចំនួនតិចជាង LMI យ៉ាងច្រើន សំរាប់អតិថិជនភាគច្រើន។
- ពុំគិតថ្លៃឈ្នួលសំរាប់ការរក្សាគណនី
- ប្រាក់ខ្ចីទិញផ្ទះដែលអាចដកចេញវិញបាន អត្រាការប្រាក់នឹងនរ ហើយអាចបំបែកបាន ព្រមទាំងមានជំរើសចំពោះធនធានផ្ទះដែលមាន។

## ការបង់សងប្រាក់ជំពាក់វិញ

HomeStart ក៏មានផ្តល់ជំរើសមួយចំនួនផងដែរ ដើម្បីជួយគ្រប់គ្រងការបង់សងប្រាក់ជំពាក់ទិញផ្ទះដែលជំពាក់របស់លោកអ្នក។ ការសងប្រាក់វិញដែលមានរបាំងសុវត្ថិភាព ‘Repayment Safeguard’ បំបែកសម្ព័ន្ធរវាងអត្រាការប្រាក់ ហើយនិងចំនួនប្រាក់បង់សងវិញ។ ប្រាក់បង់សងដំបូងរបស់លោកអ្នកមានមូលដ្ឋានលើប្រាក់ចំណូលរបស់លោកអ្នក ហើយត្រូវបានកែសំរួលមួយដងក្នុងមួយឆ្នាំ ដោយអាស្រ័យទៅលើកំរិតឡើងចុះនៃការរស់នៅជាមធ្យម។ ការនេះមានន័យថា នៅក្នុងករណីភាគច្រើន ទោះបីជាមានការអ្វីកើតឡើងដល់អត្រាការប្រាក់ក៏ដោយ ប្រាក់បង់សងវិញរបស់លោកអ្នកនឹងត្រូវផ្លាស់ប្តូរតែមួយ ដងប៉ុណ្ណោះ រៀងរាល់១២ខែ។

លោកអ្នកប្រហែលជាអាចជ្រើសរើសយកប្រភេទដើមនៃការបង់សងប្រាក់វិញផងដែរ ជាមួយនឹងការបង់សងប្រាក់វិញភ្ជាប់នឹងការប្រាក់ ‘Interest Linked Repayments’។ សូមនិយាយមកកាន់យើង អំពីជំរើសណាមួយដែលសមរម្យសំរាប់លោកអ្នក។

## តើខ្ញុំមានលទ្ធភាពខ្ចីប្រាក់ HomeStart ឬទេ?

ដើម្បីនឹងអាចមានលទ្ធភាពខ្ចីប្រាក់ លោកអ្នកត្រូវ:

- មានអាយុលើសពី១៨ឆ្នាំ
- មានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍ ឬមានសញ្ជាតិអូស្ត្រាលី
- មានបំណងនឹងរស់នៅក្នុងផ្ទះដែលលោកអ្នកទិញ
- ទិញផ្ទះនៅក្នុងរដ្ឋអូស្ត្រាលីខាងត្បូង
- មានប្រាក់ចំណូលទៀងទាត់ (នេះអាចរាប់បញ្ចូលទាំងប្រាក់បំណាច់ Centrelink)
- មានប្រាក់សន្សំចំនួន $1,000 ដែលរក្សាទុកបានយ៉ាងតិច៣ខែ ឬមានប្រវត្តិល្អចំនួន១២ខែខាងការជួលផ្ទះ ។

## របៀបចាប់អនុវត្ត

ពេលណាលោកអ្នករៀបចំខ្លួនរួចហើយ យើងអាចចាប់ផ្តើមពិនិត្យមើលជំរើសខ្ចីប្រាក់របស់លោកអ្នក ហើយផ្តល់ជូនលោកអ្នកនូវការប៉ាន់ស្មានតម្លៃផ្ទាល់ខ្លួន របស់លោកអ្នក។

ប្រសិនបើភាសាអង់គ្លេសជាភាសាទីពីររបស់លោកអ្នក ហើយលោកអ្នកនិយមនិយាយភាសារបស់លោកអ្នក យើងអាចរៀបចំឲ្យមានអ្នកបកប្រែភាសាមួយ រូបជូនលោកអ្នក។

ដើម្បីនិយាយជាមួយទីប្រឹក្សាដ៏រាក់ទាក់មួយរូបរបស់យើង សូមទូរស័ព្ទលេខ **8203 4000** ឬទូរស័ព្ទឥតគិតថ្លៃលេខ **1800 018 788** ពីទីកន្លែងនៃតំបន់ តាមជនបទ។

កិច្ចព្រមព្រៀង ល័ក្ខខ័ណ្ឌ និងលក្ខណ:វិនិច្ឆ័យលើលទ្ធភាពនឹងត្រូវអនុវត្ត។ ត្រូវបង់ចំពោះថ្លៃឈ្នួល និងប្រាក់កំរៃទាំងឡាយទៀត។ ពត៌មានត្រឹមត្រូវមកទល់នឹងខែធ្នូ ឆ្នាំ២០០៩ ហើយអាចផ្លាស់ប្តូរដោយគ្មានដំណឹង។

Khmer

ពុំអាចរកឃើញឯកសារឬ?
ដើម្បីទាញយកប្រូក្រាម Adobe Acrobat Reader សូមចុចរូបតំណាងខាងក្រោមនេះ។

ទំព័រនេះមានចុះពត៌មានអំពីប្រាក់ខ្ចីទិញផ្ទះរបស់  HomeStart។ ដើម្បីទទួលយកពត៌មានច្រើនថែមទៀត សូមទាក់ទងជាមួយ HomeStart ថ្ងៃនេះ។